**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| **ដាក់ទៅ** | : | អង្គជំនុំជម្រះសាលាដំបូង |
| **ថ្ងៃដាក់** | : | ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១១ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញា |
| **ភាសាដើម** | : | **អង់គ្លេស** |

**ឯកសារបកប្រែ**
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 04-Feb-2011, 13:53
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

**ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងញត្តិរបស់ អៀង សារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការជំនុំជម្រះលើសំណុំរឿងលេខ០០២ ទៅតាមវិសោធនកម្មនីតិវិធីដែលបានស្នើឡើង និងសំណើសុំផ្អាកជាបន្ទាន់លើដីកាបង្គាប់ឲ្យដាក់សម្ភារៈសម្រាប់ត្រៀមរៀបចំសវនាការ**

---

| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | **ចម្លងជូន:** |
|---|---|---|
| **សហព្រះរាជអាជ្ញា:** | **អង្គជំនុំជម្រះសាលាដំបូង:** | **ជនជាប់ចោទ:** |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | **នួន ជា** |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | **អៀង សារី** |
| | ចៅក្រម យ៉ា សុខន | **អៀង ធីរិទ្ធ** |
| **សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:** | ចៅក្រមJean-Marc LAVERGNE | **ខៀវ សំផន** |
| ពេជ អង្គ | ចៅក្រម យូ អុត្តរា | |
| Elisabeth SIMONNEAU FORT | | **មេធាវីការពារក្តីជនជាប់ចោទ:** |
| | | លោក សុន អរុណ |
| | | លោក Michiel PESTMAN |

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អវតក/អជសជ

លោក Victor Koppe
លោក អាង ឧត្តម
លោក Michael G.KARNAVAS
លោក ផាត់ ពៅស៊ាង
កញ្ញា Diana ELLIS QC
លោក សរ សុវ៉ាន
លោក Jacques VERGÈS
លោក Phillipe GRECIANO

១. នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១ មេធាវីការពារក្តីរបស់ អៀង សារី ("មេធាវីការពារក្តី") បានដាក់ញត្តិមួយ[1] សុំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការជំនុំជម្រះទៅតាមវិសោធនកម្មនីតិវិធីដែលបានស្នើសុំ ("ញត្តិស្នើសុំ") ជាមួយនឹងសំណើមួយទៀតសុំផ្អាកជាបន្ទាន់លើដីកាបង្គាប់ឱ្យដាក់សម្ភារៈសម្រាប់ត្រៀមរៀបចំសវនាការរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១១ ("សំណើ") ។

២. សហព្រះរាជអាជ្ញាសន្និដ្ឋានថា ទាំងញត្តិស្នើសុំ និងទាំងសំណើ គួរតែត្រូវបានបដិសេធចោល ។ មេធាវីការពារក្តី គួរតែអនុវត្តទៅតាមកាតព្វកិច្ចរបស់ខ្លួនក្រោមវិធាន ៨០ ហើយដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងឱ្យដាក់សម្ភារៈសម្រាប់ត្រៀមរៀបចំសវនាការ ចុះថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១១ ("ដីកាបង្គាប់") គួរតែត្រូវបានគោរព ដោយមូលហេតុដូចខាងក្រោម៖

ក. អង្គជំនុំជម្រះសាលាដំបូង មិនមែនជាវេទិកាត្រឹមត្រូវសម្រាប់ស្វែងរកឱ្យមានការកែប្រែវិធានផ្ទៃក្នុងទេ; ហេតុដូចនេះ ញត្តិស្នើសុំ មិនអាចទទួលយកបានឡើយ ។ តាមរយៈអង្គភាពគាំពារការការពារក្តី មេធាវីការពារក្តីគួរតែបានបញ្ជូនសំណើធ្វើវិសោធនកម្មណាមួយទៅគណៈកម្មាធិការវិធាន និងនីតិវិធី ដូចបានអនុញ្ញាតដោយវិធាន ៣ ។ វិសោធនកម្មចំពោះវិធាន ៨០ ត្រូវបានជជែកវែកញែក និងពិភាក្សាដោយកិច្ចប្រជុំពេញអង្គ ក្នុងខែកញ្ញា ឆ្នាំ២០១០ ហើយការផ្លាស់ប្តូរជាមូលដ្ឋាននៅក្នុងនីតិវិធីនាពេលនេះដែលមេធាវីការពារក្តីរបស់ អៀង សារី បានស្វែងរក គួរតែបានស្នើឡើងនៅពេលនោះ ។

ខ. វិធាន ៨០.១ និង ៨០.២ ដែលបានអនុម័តនៅខែកុម្ភៈ ឆ្នាំ២០០៨ មានលក្ខណៈចាប់បង្ខំ និងត្រូវអនុវត្តចំពោះគ្រប់ភាគីទាំងអស់ ។ មេធាវីការពារក្តីមានពេលវេលា ៣ឆ្នាំ សម្រាប់លើកពីកង្វល់ផ្សេងៗ និងដើម្បីស្វែងរកការកែសម្រួលលើវិធាន ។ មេធាវីការពារក្តីក៏មានពេលវេលាគ្រប់គ្រាន់ សម្រាប់វិភាគលើភស្តុតាងដែលបានដាក់នៅក្នុងសំណុំរឿងដែលចេះតែកើនឡើងជាលំដាប់ និងដើម្បីកំណត់អត្តសញ្ញាណសាក្សី និងឯកសារ/វត្ថុតាងដោះបន្ទុកណាមួយដើម្បីអនុវត្តទៅតាមលក្ខខណ្ឌតម្រូវនៃវិធាន ៨០.២ និង ៨០.៣ ។

គ. ញត្តិស្នើសុំ និងសំណើនេះ មានកំហុសដោយញត្តិ និងសំណើទាំងនេះ បានផ្អែកលើការយល់ខុសចំនួនពីរអំពីប្រព័ន្ធច្បាប់ស៊ីវិលគឺ៖

i. ទីមួយ ផ្ទុយទៅនឹងសំអាងរបស់មេធាវីការពារក្តីដែលថានៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល និងនៅចំពោះមុខ អ.វ.ត.ក ជាផលវិបាកដែលលេចចេញពីគោលការណ៍

---

[1] សំណុំសុំអោយអង្គជំនុំជម្រះសាលាដំបូងធ្វើការជំនុំជម្រះលើសំណុំរឿងលេខ០០២ ដោយអនុលោមតាមវិសោធនកម្មដែលបានស្នើសុំ និងសំណើសុំផ្អាកជាបន្ទាន់លើដីកាបង្គាប់ដើម្បីដាក់សម្ភារៈសម្រាប់រៀបចំសវនាការ, ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១, ឯកសារលេខ: E9/3

សច្ចធារណ៍នៃនិរទោស បន្ទុកក្នុងការបង្ហាញពិរុទ្ធភាពរបស់ជនជាប់ចោទ ស្ថិតនៅលើអយ្យការ (ដូចដែលត្រូវបានគាំទ្រដោយដើមបណ្តឹងរដ្ឋប្បវេណី) ដែលរួមទាំងនៅក្នុងពេលដែលជនជាប់ចោទឆ្លើយសារភាពអំពីបទល្មើសដែលត្រូវបានចោទប្រកាន់ផង[2] ។ អង្គហេតុពិតដែលថា បច្ចុប្បន្ននេះ ចៅក្រមទាំងឡាយបានដើរតួនាទីមួយយ៉ាងសកម្មនៅក្នុងពេលដំណើរការនីតិវិធីដើម្បីបញ្ជាក់ឱ្យឃើញនូវការពិតនោះ មិនបានផ្ទេរនូវបន្ទុកក្នុងការបង្ហាញភស្តុតាងទេ[3] ។ បន្ទាប់មកគឺ គ្មានភាពតានតឹងរវាងបន្ទុកក្នុងការបង្ហាញភស្តុតាងរបស់សហព្រះរាជអាជ្ញា ហើយនិងតួនាទីរបស់ចៅក្រមនានានៅក្នុងដំណើរការនីតិវិធីទេ ។

ii. ទីពីរ មេធាវីការពារក្តីមានការភាន់ច្រឡំអំពីការយោងទៅលើដំណើរការនីតិវិធីតាមប្រព័ន្ធ "(adversarial) ដែលបើកអោយគូភាគីមានការតទល់គ្នា" ជាមួយនឹង "នីតិវិធីចោទប្រកាន់ (accusatorial system)" ហើយដែលសន្និដ្ឋានដោយមាន

---

[2] វិធាន ៨៧ (១) និង (៥) សម្រាប់ អវតក ។ សូមអានឧទាហរណ៍សម្រាប់ ច្បាប់បែលហ្ស៊ិក Belgian Law, H.D. Bosly & D. Vandermeersch, *Droit de la Procédure Pénale*, 2001, ទំព័រ 914 [ការបកប្រែក្រៅផ្លូវការ]: "ភាគីដែលផ្តួចផ្តើមដំណើរការនីតិវិធី (...) *ត្រូវទទួលខុសត្រូវចំពោះបន្ទុកនៃភស្តុតាង* [សង្កត់ន័យបន្ថែមដោយអក្សរទ្រេត]។ នេះជាផលវិបាកតថភាពមួយនៃការសន្មតអំពីភាពស្លោះត្រង់ (...) [បន្ទុកនៃភស្តុតាង] គឺជាការទទួលខុសត្រូវទាំងស្រុងរបស់ភាគីដែលផ្តួចផ្តើមដំណើរការនីតិវិធី (ព្រះរាជអាជ្ញា និង/ឬ ដើមបណ្តឹងរដ្ឋប្បវេណី) ។ ភស្តុតាង គឺអំពីអត្ថិភាពនៃធាតុផ្សំនៃបទល្មើសទាំងអស់"; F. Kuty, *Justice Pénale et Procès Equitable*, tome 2, 2006 [ការបកប្រែក្រៅផ្លូវការ]: "វាទាញយកពីការសន្មតអំពីភាពស្លូតត្រង់ថា (...) ជនជាប់ចោទមិនទទួលខុសត្រូវលើបន្ទុកបង្ហាញភស្តុតាងចំពោះភាពស្លូតត្រង់របស់ខ្លួនទេ និងថាចៅក្រមមិនអាចរក្សាទុកបន្ទុកនៃភស្តុតាង និងក៏មិនប្រកាសការផ្តោលទោសណាមួយដែរ ប្រសិនបើអយ្យការមិនបានកំណត់ពិរុទ្ធភាពរបស់ជនជាប់ចោទ (...)" [ទទួលបានតាមរយៈ http://books.google.com/books?id=Jff KC3M4usC&pg=PA221&lpg=PA221&dq=charge+de+la+preuve+ministere+public+belgique&source=bl&ots=N21rWrP8jX&sig=kVjf9 5FhdDYOnvR9fe9ITW7GNxl&hl=en&ei=wHJGTZ6oEsX6lwfeqOU7&sa=X&oi=book_result&ct=result&resnum=7&ved=0CCwQ6A EwBg#v=onepage&q&f=false ]; ទាក់ទងនឹង ច្បាប់បារាំង សូមមើល C. Renault - Brahinsky, *Procédure Pénale*, 2007, ទំព័រ 104, ជាសៀវភៅច្បាប់បឋមដែលអ្នកនិពន្ធពន្យល់ថា [ការបកប្រែក្រៅផ្លូវការ] "ផលវិបាកនៃការសន្មតអំពីភាពស្លូតត្រង់ គឺមានន័យថា វាគឺជាភាគីដែលផ្តួចផ្តើមដំណើរការនីតិវិធី [អយ្យការ] ដែលជាអ្នកត្រូវបង្ហាញភស្តុតាងអំពីពិរុទ្ធភាពរបស់ [ជនជាប់ចោទ]", J. Pradel, *Manuel de Procédure Pénale*, កថាខ័ណ្ឌទី ៣៩៤, ទំព័រ 342 [ការបកប្រែក្រៅផ្លូវការ]: "វិធានដំបូង: ភាគីដែលផ្តួចផ្តើមដំណើរការនីតិវិធី ទទួលខុសត្រូវចំពោះបន្ទុកនៃភស្តុតាង" និង "អនុលោមតាមការសន្មតអំពីភាពស្លូតត្រង់ [ភាគីដដែល] ត្រូវ 'កំណត់រាល់ធាតុផ្សំនៃបទល្មើសទាំងអស់ (...)" ។

[3] វិធាន ៩០.១ សម្រាប់ អវតក "ចៅក្រមមានករណីកិច្ចសួរដេញដោលទាំងខាងផ្នែកដាក់បន្ទុក ទាំងខាងផ្នែកដោះបន្ទុក ចំពោះពិរុទ្ធភាពរបស់ជនជាប់ចោទ", វិធាន ៨៧ (3) & (4), 91 (1) & (2), 93; H.D. Bosly & D. Vandermeersch, *Droit de la Procédure Pénale*, 2001, ទំព័រ 916, កថាខ័ណ្ឌទី 3 [ការបកប្រែក្រៅផ្លូវការ]: "ផ្ទុយទៅនឹងនីតិវិធីរបស់ប្រទេសអង់គ្លេសដែលចៅក្រមដើរតួនាទីតែជាមជ្ឈត្តករនៅក្នុងពេលសវនាការ នៅក្រោមច្បាប់បែលហ្ស៊ិក ចៅក្រមត្រូវរួមចំណែកយ៉ាងសកម្មដើម្បីស្វែងរកការពិត ។ គោលការណ៍នេះមានន័យថា តាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ គាត់ត្រូវមានវិធានការណ៍ណាមួយដែលចាំបាច់នៅពេលដែលភស្តុតាងរួបរួមដែលប្រមូលបានមិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីនាំឆ្ពោះទៅរកការសម្រេចមួយប្រកបដោយសំអាងហេតុ ។ ជាការពិតណាស់ គាត់ត្រូវចាត់ដំណើរការនីតិវិធីដោយគ្មានលំអៀង (art. 6 ECDR)." ។

ការភាន់ច្រឡំថា ប្រព័ន្ធដែលបើកឱ្យមានការចោទសួរដេញដោល (inquisitorial system) មុខជានឹងមិនគោរពតាម លក្ខណៈនៃការបើកឱ្យគូភាគីតទល់គ្នា (adversarial) នៃនីតិវិធីនោះទេ។ ការណ៍នេះមិនបានរកឃើញមាននៅក្នុងច្បាប់ទេ ដូចដែលបានបញ្ជាក់នៅក្នុងវិធាន២១.១.ក នៃវិធានផ្ទៃក្នុងឡើយ ។ វិធានបានចែងថា ភស្តុតាងណាមួយដែលបានដាក់ជូនចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ត្រូវតែជាកម្មវត្ថុនៃការត្រួតពិនិត្យដោយគូភាគីនានា ។ ហេតុដូច្នេះ នេះមានន័យថា សហព្រះរាជអាជ្ញា មិនចាំបាច់ត្រូវបង្ហាញសំណុំរឿងទាំងមូលរបស់ខ្លួនជូនមេធាវីការពារក្ដីនៅមុនពេល ដែលមេធាវីការពារក្ដីបង្ហាញនូវភស្តុតាងដែលខ្លួនស្វែងរកការទទួលយកបាន ។ នេះគឺជាចំណុចសំខាន់នៃប្រព័ន្ធច្បាប់ស៊ីវិល និងមិននាំឱ្យមានវិការៈណាមួយនៃផ្នែកនីតិវិធីទេ ។

ឃ. នៅក្នុងព្រឹត្តិការណ៍ណាក៏ដោយ សិទ្ធិរបស់ជនជាប់ចោទ និងសច្ចធារណ៍នៃនិរទោស (presumption of innocence) ត្រូវបានធានាដោយវិធានផ្ទៃក្នុង និងដោយច្បាប់ អ.វ.ត.ក ។ នៅក្នុងក្របខណ្ឌនេះ វិធាន៨០ មានបំណងធានាពីតុល្យភាពរវាងសិទ្ធិរបស់ភាគីនានា ភាពឆាប់រហ័សនៃដំណើរការនីតិវិធី និងការគ្រប់គ្រងលើដំណើរការនីតិវិធីមួយដែលមានសណ្ដាប់ធ្នាប់ ត្រឹមត្រូវ ។

ង. មិនមានមូលហេតុណាដើម្បីឱ្យជនជាប់ចោទសុំផ្អាកលើដីកាបង្គាប់ដោយផ្អែកលើមូលដ្ឋាននៃការសន្មត់ថាមានការរំលោភសិទ្ធិរបស់ជនជាប់ចោទនោះទេ ដូចជាលើបុព្វសិទ្ធិក្នុងការប្រឆាំងនឹងការមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង ភាពមានសិទ្ធិស្មើគ្នានៅក្នុងតុលាការ ឬសិទ្ធិទទួលបាននូវផាសុបករណ៍ (Adequate facilities) ផ្សេងៗគ្រប់គ្រាន់សំរាប់ការត្រៀមរៀបចំក្នុងការការពារក្ដីរបស់ខ្លួន ។ ករណីយុត្តិសាស្ត្រដែលត្រូវបានលើកមកសំអាងដោយមេធាវីការពារក្ដី នៅក្នុងលេខយោងជើងទំព័រលេខ៥៧ និង៥៨ នៃញត្តិស្នើសុំ គឺមិនមានការទាក់ទងទេ ដូចជានៅក្នុងករណីរឿងក្ដីរបស់ Funke ទល់នឹងប្រទេសបារាំង និង J .B. w. ប្រទេសស្វីស អ្នកដាក់ពាក្យសុំត្រូវបង្ខំចិត្តក្នុងការបង្ហាញឯកសារដាក់បន្ទុកៗដ៏មានសក្ដានុពលនៅក្រោមទោសបញ្ញត្តិដោយការពិន័យ ។ ទោះជាយ៉ាងដូច្នេះក៏ដោយ នៅក្នុងករណីនេះ មេធាវីការពារក្ដីមិនត្រូវជាប់កាតព្វកិច្ចក្នុងការផ្ដល់នូវភស្តុតាងដាក់បន្ទុកណាមួយឡើយ ។ លើសពីនេះ នៅក្នុងករណីនេះ មេធាវីការពារក្ដីមានសិទ្ធិក្នុងការពិនិត្យមើលភស្តុតាង ដែលមាននៅក្នុងសំណុំរឿង ដែលស្ថិតនៅក្រោមការគ្រប់គ្រងថែរក្សារបស់ចៅក្រម ដែលឯករាជ្យនិងមិនលំអៀង ចាប់តាំងពីពេលដែលជនជាប់ចោទត្រូវបានចាប់ខ្លួនរួចមក ។ ពួកក៏បានដឹងយ៉ាងច្បាស់លាស់ផងដែរអំពីកំរិតនៃសំណុំរឿង ដូចដែលមានចែងនៅក្នុងដីកាដំណោះស្រាយ និងអំពីលក្ខណៈនិងវិសាលភាពនៃករណីការចោទប្រកាន់ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និងនៅក្នុងដីកាសន្និដ្ឋានស្ថាពរតាមវិធាន៦៦នៃវិធានផ្ទៃក្នុង

សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ និងក្នុងញត្តិស្នើសុំផ្សេងទៀតដែលសហព្រះរាជអាជ្ញាបានដាក់ជូនដែលរួមមានបញ្ជីឈ្មោះសាក្សីនានាដែលត្រូវបានដាក់ជូនថ្មីៗនេះ ។ នៅទីនេះ ជនជាប់ចោទមិនមែនតទល់គ្នាទៅតាមការកាត់ក្តីព្រហ្មទណ្ឌតាមប្រព័ន្ធច្បាប់អង់ហ្គ្លូ-សាក់សុង (Anglo-Saxon common Law) ទេ ។ គាត់កំពុងត្រូវបានកាត់ក្តីនៅក្នុងតុលាការមួយដែលមានមូលដ្ឋានជាសារវន្តតាមប្រពៃណីនៃប្រព័ន្ធច្បាប់ស៊ីវិលតាមបែបរ៉ូម៉ាំង ។ អង្គហេតុមិនបានដកហូតនូវសិទ្ធិរបស់គាត់ពីការកាត់ក្តីមួយដ៏ត្រឹមត្រូវឡើយ ។ អំណះអំណាងរបស់មេធាវីការពារក្តីបង្ហាញពីកង្វះខាតការយល់ដឹងអំពីលទ្ធភាពក្នុងការធានានូវសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការកាត់ក្តីមួយដ៏ត្រឹមត្រូវតាមប្រព័ន្ធច្បាប់ស៊ីវិល ។

ច. ការផ្អាកលើដីកាបង្គាប់នោះ គឺមុខជានឹងធ្វើឱ្យមានការអូសបន្លាយពេលវេលានៃដំណើរការនីតិវិធីដោយមិនសមស្រប និងរំលោភទៅលើគោលការណ៍ស្តីពីការសន្សំសំចៃថវិការបស់តុលាការ និងប្រសិទ្ធិភាព ព្រមទាំងសិទ្ធិរបស់ជនជាប់ចោទរូបនេះ និងជនជាប់ចោទដទៃទៀត ដែលត្រូវទទួលបាននូវការជំនុំជំម្រះក្តីដោយគ្មានការអូសបន្លាយពេលវេលាដោយមិនសមស្រប ។

៣. សហព្រះរាជអាជ្ញា កត់សំគាល់ថា មេធាវីការពារក្តីហាក់ដូចជាបានផ្តល់នូវសេចក្តីពិស្តារ ឬច្បាប់ចម្លងនៃញត្តិស្នើសុំ និងសំណើសុំមួយច្បាប់ៗទៅឱ្យសារពត៏មាន The Cambodia Daily នៅមុនពេលអង្គជំនុំជម្រះសាលាដំបូង ធ្វើចំណាត់ថ្នាក់ឯកសារទាំងនេះ និងធ្វើការជូនដំណឹងដល់ភាគីនានា[4] ។ តាមពិត អត្ថបទនៅក្នុង The Cambodia Daily បានចេញផ្សាយនៅថ្ងៃទី ២៧ ខែមករា ឆ្នាំ២០១១ ហើយសហព្រះរាជអាជ្ញា និងភាគីផ្សេងទៀតមិនបានទទួលអត្ថបទមិនផ្លូវការនេះពីមេធាវីការពារក្តី រហូតទាល់តែម៉ោង ៣:៤២ រសៀល នៅថ្ងៃដដែល[5] ។

៤. ហាក់ដូចជាមិនត្រឹមត្រូវទេ ដែលថា ការជូនដំណឹងលើកទី១ដល់គ្រប់ភាគីទាំងអស់អំពីសេចក្តីថ្លែងសំអាងអំពីអង្គច្បាប់ត្រូវបានធ្វើតាមរយៈប្រព័ន្ធផ្សាយពត៏មាន ។ ប្រការដែលមេធាវីការពារក្តីបានសាកល្បងដោយមិនត្រឹមត្រូវក្នុងការដាក់ញត្តិ និងសំណើសុំជាភាសាអង់គ្លេសតែប៉ុណ្ណោះគត់កាលពីថ្ងៃទី២៤ ខែមករា ឆ្នាំ២០១១ នោះ គឺមិនអាចលើកលែងឱ្យបានទេ ហើយតាមពិតគឺវាជួយធ្វើឱ្យកាន់តែគ្រោះថ្នាក់ក្នុងការ "ដំណើរការរឿងក្តីតាមផ្លាយរណប" នៅក្នុងប្រព័ន្ធផ្សាយព័ត៌មាននៅក្នុងពេលដែលដំណើរការរឿងក្តីផ្លូវការតាមផ្លូវតុលាការមិនទាន់ត្រូវបានបំពេញ

[4] *អត្ថបទកាសែត The Cambodia Daily,* ដែលមានចំណងជើងថា "*មេធាវី អៀង សារី ដាក់សម្ពាធឱ្យផ្លាស់ប្តូរនីតិវិធី*"។

[5] អ៊ីម៉េល ថ្ងៃទី ២៧ មករា ២០១១ ពី Neville Sorab (សម្រាប់ អៀង សារី) ដល់គូភាគី ផ្តល់ច្បាប់ចម្លងជាការសមរម្យ នៃសំណើរបស់ អៀង សារី សុំបង្អង់ការដាក់ជាភាសាអង់គ្លេសពីដើមដំបូងជាមួយនឹងការបកប្រែជាភាសាខ្មែរ & សំណើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការជំនុំជម្រះលើសំណុំរឿង ០០២ ដោយអនុវត្តតាមវិសោធនកម្មនីតិវិធីដែលបានស្នើឡើង និងសំណើសុំផ្អាកជាបន្ទាន់លើដីកាបង្គាប់ដើម្បីដាក់សម្ភារៈសម្រាប់រៀបចំសវនាការ ។

គ្រប់គ្រាន់ដោយភាគីនៅឡើយ[6]។ សហព្រះរាជអាជ្ញា ក៏សូមរំឭកឡើងវិញផងដែរថា ភាគីទាំងឡាយចាំបាច់ត្រូវតែឈប់បញ្ចេញព័ត៌មានជាសាធារណៈអំពីឯកសារនានា ដែលដាក់ជូនទៅតុលាការ នៅមុនពេលអង្គជំនុំជម្រះសាលាដំបូងនេះធ្វើចំណាត់ថ្នាក់ឯកសារទាំងនេះថាជាសាធារណៈ ។ សហព្រះរាជអាជ្ញា សូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង ចេញការណែនាំមួយលើបញ្ហានេះទៅដល់គ្រប់ភាគីទាំងអស់ រួមទាំងសហព្រះរាជអាជ្ញាផង ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញា | | [signature] |

---

[6] *សូមអាន* អ៊ីម៉េល ពី Seville Sorab ដែលផ្ញើជូន អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃ០១ កុម្ភៈ ២០១១ ដែលពន្យល់អំពីមូលហេតុថាតើហេតុអ្វីបានជាមេធាវីរបស់ អៀង សារី មានបំណងចង់ដាក់ឯកសារតែជាភាសាអង់គ្លេសប៉ុណ្ណោះ កាលពីថ្ងៃទី២៤ មករា ២០១១។